ធ៧-០១-១១៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនិងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគមចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួនឱ្យបានស្របតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ២**.-

ការប្រាក់ចំពោះឥណទានដែលបានផ្តល់ឱ្យតាមខ្លឹមសារនៃប្រកាសនេះ ត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយបានន័យថា ការប្រាក់លើឥណទានសម្រាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ។

**ប្រការ ៣**.-

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជនត្រូវមានបង្ហាញតារាងពីការសងរំលោះឥណទាន។

**ប្រការ ៤**.-

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**